01581835

**Declassified to Public 19 December 2018**

E378/8/10

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 08 / 2018
ម៉ោង (Time/Heure): 13:45
មន្ត្រីមទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

លេខ ៥១៥ /សសគម/១៨

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨

**ប្រធានគណៈមេធាវី**
**មេធាវី សួន ចិសាល**
**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង ចណ្ណៈ
២-មេធាវី អ៊ឹង គិរីយ៉ា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ឹម ប៉ុលី
៥-មេធាវី ឡៀម សំបុរ
៦-មេធាវី ជា សុកខួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ផាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃឹម
១៣-មេធាវី លឹម សុចណ្ណា
១៤-មេធាវី ឈឹម គិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង ហានខួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី គឹង
១៩-មេធាវី យឹម ចិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ ចិសាល
២២-មេធាវី ហូ លីហួច
២៣-មេធាវី ទ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ចិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់មេធាវីបរទេសលោក Victor Koppe ជាសហមេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា ក្នុងសំណុំរឿង ០០២/០២ ឲ្យនៅក្រៅបញ្ជី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវីចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវីចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបោះឆ្នោតជ្រើសតាំងមេធាវី **សួន ចិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១១
- យោងតាមលិខិតរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាលេខ ៧៨៨/គ.ម/០៧ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការចុះឈ្មោះមេធាវីបរទេសក្នុងបញ្ជីនៃគណៈមេធាវីកម្ពុជា ដើម្បីការពារក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- យោងតាមលិខិតលេខ E378/8/4 ចុះថ្ងៃទី៣១ ឧសភា ២០១៨ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ស្តីពីការសាកសួរគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងឋានៈមេធាវីរបស់លោក Victor Koppe ជាសហមេធាវីអន្តរជាតិការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០២
- យោងតាមលិខិតលេខ ១៦១២/គម/១៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១៨ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលឆ្លើយតបនឹងសំណួររបស់ អ.វ.ត.ក ។
- យោងតាមលិខិតរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាលេខ ១៧៩៤/គម/១៨ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការការស្នើសុំឯកសារផ្តល់ឯកសារមកគណៈមេធាវីនៃព្រះរាជា/

ណាចក្រកម្ពុជា ទាក់ទងនឹងឋានៈរបស់លោក Victor Koppe ក្នុងគណៈមេធាវីបរទេសរបស់គាត់

- យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៨
- ដោយហេតុថា យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មេធាវីបរទេសអាចចុះបញ្ជីនៅក្នុងបញ្ជីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លុះត្រាតែមេធាវីនោះត្រូវបានប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈមេធាវី។

- ដោយហេតុថា ពាក្យថា "ប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈមេធាវី" នៅក្នុងមាត្រា ៥ ខាងលើ បើគិតទៅតាមពេលវេលា សិទ្ធិប្រកបវិជ្ជាជីវៈមេធាវីនៅប្រទេសដើម ត្រូវតែដើរស្របពេលគ្នាជាមួយសិទ្ធិប្រកបវិជ្ជាជីវៈមេធាវីនៅប្រទេសកម្ពុជា។ មានន័យថា បើការទទួលស្គាល់នៅប្រទេសដើមត្រូវបញ្ចប់ដោយប្រការណាមួយ ការប្រកបវិជ្ជាជីវៈនៅប្រទេសកម្ពុជាក៏ត្រូវបញ្ចប់ជាមួយគ្នាដែរ ព្រោះការដែលគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមចុះបញ្ជីមេធាវីបរទេសណាម្នាក់នៅក្នុងបញ្ជីរបស់ខ្លួន ក៏ដោយសារតែគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់បុគ្គលដែលសុំចុះបញ្ជីនោះមានឋានៈជាមេធាវីដែរ។ ដូច្នេះ កាលណាបុគ្គលនោះបាត់បង់ឋានៈជាមេធាវីនៃប្រទេសដើមរបស់ខ្លួន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក៏មិនអាចទទួលស្គាល់បុគ្គលនោះក្នុងឋានៈជាមេធាវីបានឡើយ ហើយបុគ្គលនោះក៏មិនអាចប្រកបវិជ្ជាជីវៈមេធាវីក្នុងដែនយុត្តាធិការកម្ពុជាបានដែរ។
- ដោយហេតុថា កាលណាមេធាវីណាម្នាក់ ទោះជាខ្មែរក្តី ជាបរទេសក្តី បានចុះបញ្ជីក្នុងបញ្ជីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួចហើយ មេធាវីនោះត្រូវស្ថិតនៅក្រោមវិធាននៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដូចគ្នា។ កាលណាមេធាវីណាម្នាក់បាត់បង់លក្ខណៈសម្បត្តិជាមេធាវី មេធាវីនោះត្រូវដាក់ឱ្យស្ថិតនៅក្រៅបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ដោយហេតុថា យោងតាមមាត្រា៤១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលចែងថា "ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជី បើមេធាវីនោះស្ថិតក្នុងស្ថានភាពវិសមិតភាព ឬមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន។ ក្នុងករណីមានបណ្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចខាងលើ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣"
- ដោយហេតុថា យោងតាមមាត្រា ៣៣ សាមីមេធាវីដែលរងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីអាចប្តឹងតវ៉ាបាន តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៥ ពោលគឺសាមីមេធាវីមានសិទ្ធិប្តឹងឧទ្ធរណ៍ទល់នឹងសេចក្តីសម្រេចជាមួយសាលាឧទ្ធរណ៍ ក្នុងរយៈពេលពីរខែចាប់ពីថ្ងៃទទួលដំណឹងនៃសេចក្តីសម្រេច
- ដោយហេតុថា យោងតាមឯកសាររបស់លោកមេធាវី Victor Koppe ដែលអ.វ.ត.ក បានផ្តល់មកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកភាពរបស់លោក Victor Koppe នៅក្នុងគណៈមេធាវី Amsterdam បានចប់នៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦។

01581837

E378/8/10

# ស ម្រេ ច

ប្រការ ១.- ដាក់សហមេធាវីអន្តរជាតិលោក Victor Koppe ឱ្យនៅក្រៅបញ្ជីនៃសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៨ តទៅ។

ប្រការ ២.- សហមេធាវីអន្តរជាតិលោក Victor Koppe មិនអាចប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងដែនយុត្តាធិការកម្ពុជាបានឡើយ ។

ប្រការ៣.- សាមីខ្លួន ក្នុងករណីមិនយល់ស្របនឹងសេចក្តីសម្រេចនេះអាចប្តឹងទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់តាំងពីថ្ងៃទទួលសេចក្តីសម្រេចនេះ ដោយអនុលោមតាមមាត្រា ២៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ប្រការ ៤.- សេចក្តីសម្រេចទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.- អគ្គលេខាធិការ នាយកដ្ឋានពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

**ត.ប ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**អគ្គលេខាធិការរង**

ពេជ្រ ឃុំ . ឆារ

**ចម្លងជូន ÷**

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

-អង្គភាពគាំពារការការពារក្តីនៃ អ.វ.ត.ក

-រដ្ឋបាល អ.វ.ត.ក

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ប្រធានសាលាឧទ្ធរណ៍

-ឯកសារ-កាលប្បវត្តិ